

## ជំពូកទី៥

# តើកូនអ្នកអាចស្តាប់ឮអ្វីខ្លះ?




កុមារមួយចំនួនគឺថ្លង់ទាំងស្រុង មិនអាចស្តាប់ឮអ្វីទាំងអស់ ឬក៏អាចឮតែសម្លេងខ្លាំងៗប៉ុណ្ណោះ។ ពេលទារកនៅតូចពេក ឪពុកម្តាយសំគាល់ឃើញថា កូនតូចរបស់ពួកគាត់មិនអាចស្តាប់ឮដោយសារទារកមិនងាកក្បាល ឬមិនឆ្លើយតប ទោះបីជាមានសម្លេងខ្លាំងក៏ដោយ។




កុមារជាច្រើនទៀតដែលបាត់បង់ការស្តាប់ខ្លះៗ អាចនៅស្តាប់ឮសម្លេងតិចតួចដែរ។ ចំពោះភាពបាត់បង់ការស្តាប់ឮប្រភេទនេះ ឪពុកម្តាយកាន់តែពិបាកសំគាល់ថែមទៀត។ កុមារអាចបង្ហាញការភ្ញាក់ផ្អើល ឬក៏ងាកក្បាលទៅរកសម្លេងដែលឮខ្លាំង តែមិនភ្ញាក់ផ្អើលចំពោះសម្លេងខ្សោយជាងនោះឡើយ។ កុមារអាចឆ្លើយតបចំពោះប្រភេទសម្លេងមួយចំនួនតែប៉ុណ្ណោះ។

កុមារមួយចំនួនអាចនៅស្តាប់ឮបានតិចតួច ពេលមនុស្សនិយាយរកពួកគេ។ ពួកគេរៀនសន្សឹមៗទើបស្គាល់ និងចេះឆ្លើយតបចំពោះពាក្យខ្លះៗ។ ប៉ុន្តែពួកគេមិនបានឮគ្រប់ពាក្យ ឱ្យគ្រប់គ្រាន់ច្បាស់លាស់ដើម្បីយល់នោះទេ។ កុមារបាត់បង់ការស្តាប់ឮប្រភេទនេះ រៀនយូរណាស់ទើបចេះនិយាយ។

ការស្តាប់ឮរបស់កុមារជាច្រើន ចុះខ្សោយដោយសាររលាកត្រចៀកជាញឹកញាប់ និងដំបៅយូរពេក ឬក៏បណ្តាលពីឥទ្ធិពលនៃប្រភេទថ្នាំមួយចំនួន (សូមអានជំពូកទី15 ស្តីពីហេតុអ្វីកុមារបាត់បង់ការស្តាប់ឮ និងអ្វីៗដែលយើងអាចធ្វើបាន។ ឪពុកម្តាយអាចមិនបានសំគាល់ថា ការស្តាប់របស់កូនបានថយចុះយឺតៗនោះទេ ទាល់តែកូនមានអាយុ4 ឬ5ឆ្នាំ ហើយមិនទាន់ចេះនិយាយ ឬនិយាយមិនច្បាស់។

បើសិនជាអ្នកអាចសំគាល់ឃើញភ្លាមៗថា កូនអាចស្តាប់ឮបានច្រើនប៉ុណ្ណា នោះអ្នកអាចដឹងរបៀបត្រូវជួយកូនបន្ថែមទៀត ដើម្បីឱ្យកូនអាចប្រាស្រ័យទាក់ទងបាន។ ពេលខ្លះឪពុកម្តាយ កុមារឯទៀត ឬគ្រូបង្រៀនគិតថា កុមារដែលបាត់បង់ការស្តាប់ គឺមានគំនិតប្រាជ្ញាអន់ថយ។ បើសិនជាកុមារថ្លង់ត្រូវបានជួយជ្រោមជ្រែងបន្ថែមដើម្បីរៀនប្រាស្រ័យទាក់ទង នោះកុមារថ្លង់ស្ទើរតែទាំងអស់អាចរៀន និងចេះដឹងដូចកុមារដទៃទៀតដែរ។ នោះជាហេតុផលសំខាន់ដើម្បីរកឱ្យឃើញសម្លេងអ្វីៗ ទោះជាសម្លេងស្អឹកក៏ដោយ ឱ្យតែកុមារអាចនៅស្តាប់ឮ។

## ការយល់ពីសម្លេង

បើសិនជាឪពុកម្តាយដឹងពីប្រភេទសម្លេងខុសៗគ្នា វានឹងជួយពួកគេឱ្យយល់ថា សម្លេងច្រើនប៉ុណ្ណា និងសម្លេងប្រភេទណាដែលកូនរបស់ពួកគេអាចស្តាប់ឮ។

### ភាពខ្លាំងនៃសម្លេង

សម្លេងខ្លះ គឺឮខ្លាំងជាងសម្លេងដទៃ។ សូរសម្លេងនៅជិត គឺឮខ្លាំងជាងសូរសម្លេងដដែលនោះពេលនៅឆ្ងាយ។



**សម្លេងម៉ូតូ គឺឮខ្លាំងជាងសម្លេងមនុស្សដើរ។ ពេលម៉ូតូមួយបើកមកជិត សម្លេងវាឮខ្លាំងជាងម៉ូតូបើកនៅឆ្ងាយ។**

សម្លេងខ្លះអាចធ្វើឱ្យឮខ្លាំងជាង ឬស្ងាត់ជាង។ ឧទាហរណ៍ អ្នកអាចបង្កើនវ៉ុល្លឹមវិទ្យុឱ្យឮខ្លាំង ឬអ្នកអាចធ្វើសម្លេងរបស់អ្នកឱ្យស្ងាត់ជាង ដោយដូរពីសម្លេងស្រែកទៅជាសម្លេងខ្សិប។




### កំរិតសូរសម្លេង

កំរិតសូរសម្លេង គឺជារបៀបប្រាប់ឱ្យដឹងសូរសម្លេងឡើងខ្ពស់ ឬថយចុះ។ ដូចជាតន្ត្រី សម្លេងភ្លេងអាចឡើងចុះពីកំរិតខ្ពស់ទៅកំរិតទាប។

**សូរសម្លេងកំរិតខ្ពស់**




សូរសម្លេងកំរិតខ្ពស់ មានសម្លេងមុតស្រាល អ្នកអាចទទួលអារម្មណ៍ថាចូលពេញក្នុងត្រចៀកអ្នក។

**សូរសម្លេងកំរិតទាប**




សូរសម្លេងកំរិតទាប មានសម្លេងធ្ងន់ពេញណែន ដែលអ្នកអាចទទួលអារម្មណ៍ដល់ឆ្អឹង (ដឹងដោយអព្ភន្តរញ្ញាណ)។

សម្លេងនិយាយប្លែកៗគ្នា ក៏មានសូរសម្លេងកំរិតខ្ពស់ ឬទាបខុសពីគ្នាដែរ ។ ឧទាហរណ៏សម្លេង "អូ" និង "ម" (តុង ឬខ្យល់នៃសម្លេង) មានសូរសម្លេងកំរិតទាប ។ សម្លេង "អ៊ី" មានសូរសម្លេងកំរិតកណ្តាល ។ សម្លេង "ស៊ី" និង "ហ្វ" មានសូរសម្លេងកំរិតខ្ពស់ ។

## ការបាត់បង់ការស្តាប់ឮមានច្រើនប្រភេទ

ធម្មតាកុមារមានបញ្ហាក្នុងការស្តាប់ មានការលំបាកទាំងភាពខ្លាំងនៃសម្លេង និងកំរិតសូរសម្លេង ។ ឧទាហរណ៏ :-

ទារកនេះ មិនអាចស្តាប់ឮល្អ ។ ទារកនេះ មិនអាចស្តាប់ឮ**សូរសម្លេងកំរិតខ្ពស់ ។**



ទារកមិនអាចស្តាប់ឮឪពុកផ្លុំខ្លុយឡើយ ប៉ុន្តែទារកនេះ អាចស្តាប់ឮសូរសម្លេងកំរិតទាប សម្លេងឮខ្លាំង ដូចជាសម្លេងស្គរ ។

កុមារានេះ មិនអាចស្តាប់ឮល្អទេ ។ ក្មេងនេះ មិនអាចស្តាប់ឮ**សូរសម្លេងកំរិតទាប ។**



កុមារានេះ មិនអាចស្តាប់ឮសម្លេងស្គរ ដែលឪពុកកំពុងលេងឡើយ ។ ផ្ទុយមកវិញ ក្មេងនេះទទួលអារម្មណ៏ខ្ទ័រពីសម្លេងស្គរ (ញ័រ) ប៉ុន្តែកុមារានេះ អាចស្តាប់ឮសូរសម្លេងកំរិតខ្ពស់ ដូចជា សម្លេងទារកយំ ។

កុមារីនេះ មិនអាចស្តាប់ឮល្អ ។ នាងមិនអាចស្តាប់ឮ**សូរសម្លេងកំរិតកណ្តាល** ។



កុមារីនេះ អាចស្តាប់ឮសូរសម្លេងកំរិតខ្ពស់ ដូច្នេះនាងអាចឮសម្លេងទារកយំ ។ នាងក៏អាចឮសម្លេងឪពុកនិយាយផងដែរ ប៉ុន្តែនាងមិនអាចឮសម្លេងម្តាយនិយាយ ។

កុមារានេះ ថ្លង់ទាំងស្រុង ។ ក្មេងនេះ មិនអាចស្តាប់ឮ**សម្លេងអ្វីទាំងអស់** ។



កុមារានេះ មិនអាចស្តាប់ឮសម្លេងម្តាយ សម្លេងមាន់ស្រែក នៅសំយ៉ាបផ្ទះ ឬសម្លេងរថយន្តធំៗបើកតាមផ្លូវ ទោះជាសម្លេងនោះ ខ្លាំងយ៉ាងណាក៏ដោយ ។

# តើកូនអ្នកអាចស្តាប់ឮសម្លេងអ្វីខ្លះ?

បើសិនជាកូនអ្នកអាចស្តាប់ឮបានតិចតួច ការស្វែងរកឱ្យឃើញសម្លេងណាមួយដែលកូនអាចស្តាប់ឮ នោះវានឹងជួយដល់អ្នក។ កាលណាអ្នកដឹងកាន់តែច្រើនអំពីការស្តាប់របស់កូន អ្នកអាចប្រាស្រ័យទាក់ទងជាមួយកូនកាន់តែប្រសើរ ទៅតាមវិធីដែលកូនអាចយល់បាន។

## កត់សំគាល់របៀបដែលកូនអ្នកឆ្លើយតបទៅនឹងសម្លេង

ពេលកុមារស្តាប់ឮសម្លេងមួយ យើងអាចពិបាកដឹងណាស់ថា គេបានឮសម្លេងនោះ ជាពិសេសចំពោះកុមារតូចៗ។ អ្នកនឹងដឹងថា កូនអ្នកបានឮសម្លេងមួយ ពីព្រោះកុមារអាច :-

- លើកដៃ និងលើកជើង
- ផ្លាស់ប្តូរទឹកមុខ
- ស្រាប់តែនៅស្ងៀមមួយរំពេច
- ធ្វើសម្លេងដោយខ្លួនឯង
- ញញឹម ឬ សើច
- ងាកទៅរក ឬងើយក្បាលស្តាប់សម្លេង
- ភ្ញាក់ បើកភ្នែកធំៗ ឬព្រិចភ្នែក




### តើកូនអ្នកទំនងជាឮសម្លេងខ្លះៗឬទេ?

សង្កេតមើលកុមារឱ្យបានជិតដល់នៅពេលថ្ងៃ ដើម្បីរកឱ្យឃើញនូវអ្វីដែលកុមារអាចស្តាប់ឮថែមទៀត និងសួរខ្លួនអ្នកថា :-

- តើក្មេងមានបង្ហាញអ្វីមួយថា គេទំនងជាស្តាប់ឮសូរសម្លេងកំរិតខ្ពស់ឬទេ? ឬសូរសម្លេងកំរិតទាបស្មើរតែទាំងអស់? ឬក៏ចំរុះគ្នាទាំងពីរកំរិត?
- កុមារស្តាប់ឮតែនៅពេលខ្លះ ហើយមិនឮគ្រប់ពេលឬយ៉ាងណា?
- តើកុមារអាចឮសម្លេង នៅពេលដែលបន្ទប់ស្ងាត់តែប៉ុណ្ណោះឬ?
- តើសម្លេងត្រូវតែបន្លឺឱ្យខ្លាំង ដើម្បីឱ្យក្មេងបានឮវាឬ?



ពេលបន្ទប់ស្ងាត់ *កូហ៊ី*អាចឮសម្លេងដុំឈើធ្លាក់ចុះ។



*កូហ៊ី*អាចមិនឮសម្លេងដុំឈើធ្លាក់ នៅពេលបន្ទប់មានសម្លេងផ្សេងៗលាយឡំ។

## ពិនិត្យការស្តាប់របស់កុមារនៅផ្ទះ

ពិនិត្យការស្តាប់របស់កុមារតូចគឺជាការពិបាកណាស់។ វាមានប្រយោជន៍ចំពោះអ្នក បើអ្នកអាចពិនិត្យការស្តាប់របស់កូនដោយខ្លួនឯងជាមុនសិន ទោះបីជាអ្នកគ្រោងយកកូនទៅធ្វើតេស្តការស្តាប់ដោយអ្នកឯកទេសក៏ដោយ។ ធ្វើបែបនេះ អ្នកអាចផ្តល់ព័ត៌មានទៅអ្នកឯកទេស ហើយអ្នកយល់បានល្អប្រសើរនូវអ្វីដែលអ្នកឯកទេសកំពុងធ្វើ។



ពិនិត្យការស្តាប់នៅផ្ទះមិនចំណាយថវិកា និងប្រើសំភារៈដែលងាយស្រួលរកផងដែរ។ ពិនិត្យការស្តាប់របស់កូនដោយខ្លួនអ្នកផ្ទាល់ នឹងផ្តល់ទំនុកចិត្តយ៉ាងច្រើនដល់ការសំរេចចិត្តរបស់អ្នកលើការថែទាំ និងអភិវឌ្ឍកូន។ វាគឺជាវិធីល្អផងដែរ សំរាប់មិត្តភ័ក្តិ និងសមាជិកគ្រួសារចូលរួមឱ្យបានច្រើន ខណៈដែលកូនអ្នករៀនប្រាស្រ័យទាក់ទង ។

សូមចាំទុកថា កូនអ្នកអាចឆ្លើយតបចំពោះ :-

- អ្វីដែលក្មេងបានឃើញ តែមិនមែនជាសម្លេងបានឮ។
- ភាពខ្ទ័រ (ញ័រ) ដែលសម្លេងខ្លាំងបានបន្លឺឡើង។
- ទឹកមុខដែលអ្នកបានបង្ហាញ ឬកាយវិការរបស់អ្នក។

កូនអ្នកអាចមិនឆ្លើយតប បើសិនជា :-

- កូនកំពុងរវល់ធ្វើអ្វីមួយ។
- កូនឈឺ ឬកើតដំបៅត្រចៀក។
- កូននឿយហត់ ធុញទ្រាន់ ឬមិនស្រួលចិត្ត។

## របៀបពិនិត្យការស្តាប់របស់កូន

ព្យាយាមកត់សំគាល់សម្លេងដែលកូនឆ្លើយតប ចំពោះសកម្មភាពកើតឡើងរាល់ថ្ងៃ។ នេះជាវិធីល្អទូទៅមួយ ដើម្បីរៀនអំពីការស្តាប់របស់កូន។ បន្ទាប់ទៀត អ្នកអាចពិនិត្យសម្លេងណាដែលកូនអាចស្តាប់ឮ និងមិនអាចស្តាប់ឮ។ ដំបូងអ្នកពិនិត្យមើលសម្លេងអ្វីៗដែលកូនបានឮចេញពីវត្ថុខុសគ្នានីមួយៗ និងសម្លេង "និយាយ" ដែលកូនបានស្តាប់ឮ នៅពេលមនុស្សនិយាយគ្នា។



ដើម្បីអនុវត្តរបៀបនេះ អ្នកត្រូវការ :-

- កន្លែងស្ងាត់មួយ គ្មានសូរ ឬសម្លេងអ្វីមករំខាន។
- ឧបករណ៍សាមញ្ញខ្លះៗ។
- មនុស្សពីរនាក់ ដើម្បីជួយដល់អ្នក។

ដំបូងពិនិត្យការស្តាប់នៃកុមារម្នាក់ដែលស្តាប់ឮធម្មតា មានអាយុស្រករនឹងកូនអ្នក។ អនុវត្តទាល់តែអ្នកមើលឃើញនូវរបៀបដែលកុមារស្តាប់ឮធម្មតាម្នាក់នេះ ឆ្លើយតបទៅសម្លេងដែលគេបានឮ។

- រក្សាបរិយាកាសក្នុងពេលពិនិត្យការស្តាប់តាមសម្រួល និងរីករាយ ។
- ប្រើសម្ភារៈជាប្រដាប់លេងតូចៗផ្សេងៗពីគ្នា ដើម្បីកុំឱ្យកុមារធុញទ្រាន់ ។
- រក្សារយៈពេលពិនិត្យឱ្យខ្លី ។ អ្នកអាចធ្វើការពិនិត្យការស្តាប់ឱ្យបានច្រើនជាងមួយលើក ។

## ▶ ពិនិត្យចំពោះភាពខ្លាំងនៃសម្លេង និងកំរិតសូរសម្លេង

**អ្នកជួយម្នាក់** អង្គុយនៅពីមុខម្តាយ និងកុមារ ។ អ្នកជួយត្រូវទាក់ទាញការយកចិត្តទុកដាក់របស់កុមារ ដោយបង្ហាញប្រដាប់លេងតូចមួយ ។




**អ្នកធ្វើតេស្ត**ជាមនុស្សម្នាក់ផ្សេងទៀត ត្រូវឈរចម្ងាយមួយម៉ែត្រពីក្រោយខ្នងម្តាយកុមារ និងក្រៅខ្សែចក្ខុរបស់កុមារ ។ ដើម្បីឱ្យក្មេងឮសម្លេងរបស់អ្នកធ្វើតេស្ត ចូរធ្វើសម្លេងម្តងមួយចំហៀងខ្លួនរបស់ក្មេង ។ អ្នកធ្វើតេស្តមិនគួរញញឹម ឬមើលតបទៅកុមារឡើយ បើសិនជាកុមារងាកមើលទៅគាត់ ។

### អ្នកត្រូវការអ្វីខ្លះ សំរាប់ពិនិត្យការស្តាប់

ការធ្វើតេស្តនេះ អ្នកប្រើសម្លេងសាមញ្ញៗធ្វើពីកំប៉ុងដែកស័ង្កសី ចំនួនបីមានទំហំប៉ុនៗគ្នា ។

1. ដាក់បំណែកឈើមួយ ទៅក្នុងកំប៉ុងទីមួយ (សូរសម្លេងកំរិតទាប)



2. ដាក់គ្រាប់សណ្តែកឆៅមួយក្តាប់ធំទៅក្នុងកំប៉ុងទីពីរ (សូរសម្លេងកំរិតកណ្តាល)



3. ដាក់គ្រាប់អង្ករមួយក្តាប់ ទៅក្នុងកំប៉ុងទីបី (សូរសម្លេងកំរិតខ្ពស់)



ក្រឡុកកំប៉ុងថ្នមៗសំរាប់ធ្វើសម្លេង**ស្ងាត់**មួយ ។ ក្រឡុកកំប៉ុងខ្លាំងជាងមុនបន្តិច សំរាប់ធ្វើសម្លេង**កណ្តាល**មួយ ។ ក្រឡុកកំប៉ុងឱ្យខ្លាំងសំរាប់ធ្វើសម្លេង**ខ្លាំង**មួយ ។ អ្នកធ្វើតេស្តគួរអនុវត្តក្រឡុកកំប៉ុងនីមួយៗ ទាល់តែគាត់អាចគ្រប់គ្រងបានភាពខ្លាំងនៃកំរិតសម្លេងទាំងបី ( ក្រឡុកប៉ុណ្ណាដើម្បីកំណត់ថាជាសម្លេងស្ងាត់ ជាសម្លេងកណ្តាល និងជាសម្លេងខ្លាំង) ។

**របៀបកត់ត្រាសម្លេងដែលកុមារស្តាប់ឮ**

នេះជាវិធីធ្វើតារាងមួយ ដើម្បីកត់ត្រាសម្លេងអ្វីខ្លះដែលកុមារស្តាប់ឮ។ តារាងមានផ្នែកមួយ សំរាប់ត្រចៀកម្ខាងៗ។ ផ្នែកនីមួយៗមានប្រអប់សំរាប់សម្លេងកំរិតទាប (ស្ងាត់ ឬថ្នម) កំរិតកណ្តាល និងកំរិតខ្ពស់។

បើសិនជាកុមារបានឮសម្លេងនីមួយៗ អ្នកគូសក្នុងប្រអប់នីមួយៗ សម្លេងស្ងាត់ (1 រង្វង់) សម្លេងកណ្តាល (2 រង្វង់) ឬសម្លេងខ្លាំង (3 រង្វង់)។ កុំគូសរង្វង់ បើសិនជាកុមារមិនអាចស្តាប់ឮសម្លេងអ្វីសោះ ទោះជាអ្នកក្រឡុកកំប៉ុងខ្លាំងយ៉ាងណាក៏ដោយ។




○ **សម្លេងថ្នម** ◎ **សម្លេងកណ្តាល** ◎ **សម្លេងខ្លាំង**

**ការធ្វើតេស្តកុមារ**

**អ្នកជួយ:** ប្រើប្រដាប់លេងតូចមួយដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីកុមារដោយចិត្តស្ងប់ស្ងាត់។ ដៃម្ខាងកាន់ប្រដាប់លេងតូច និងយកដៃម្ខាងទៀតគ្របពីលើវាថ្នមៗ នៅពេលកុមារផ្តោតការយកចិត្តទុកដាក់ទៅលើប្រដាប់លេងនោះ។



**អ្នកធ្វើតេស្ត:** ក្រឡុកកំប៉ុងដើម្បីធ្វើសូរសម្លេងកំរិតទាប។ គ្របមាត់កំប៉ុង ហើយក្រឡុកវាចំនួនបីបួនវិនាទី នៅខាងក្រោយត្រចៀក**ម្ខាងៗ**របស់កុមារ។ ដំបូងចូរធ្វើសម្លេងស្ងាត់មួយ។

**អ្នកជួយ និងម្តាយ:** សំគាល់មើល បើសិនជាកុមារមានការឆ្លើយតបទៅនឹងសម្លេង។

**អ្នកជួយ:** ចូរងក់ក្បាលតិចៗជាសញ្ញា បើសិនជាកុមារឆ្លើយតបដើម្បីប្រាប់អ្នកធ្វើតេស្តថា កុមារបានឆ្លើយតបទៅសម្លេងនោះ។

## តើកូនអ្នកអាចស្តាប់ឮអ្វីខ្លះ?




**អ្នកធ្វើតេស្ត:** បើសិនជា កុមារ**ឆ្លើយតបទៅ**សម្លេងស្ងាត់ ចូរគូសមួយរង្វង់ក្នុងតារាង និងឈប់ធ្វើតេស្តសូរសម្លេងកំរិតទាបនៅត្រចៀកនោះ ។

បើសិនជាកុមារ**មិនឆ្លើយតប**ទៅសម្លេងស្ងាត់ ចូរក្រឡុកកំប៉ុងឱ្យឮខ្លាំងជាងមុនបន្តិច ប្រមាណបីបួនវិនាទី ដើម្បីធ្វើសូរសម្លេងកំរិតកណ្តាល ។ ចូរចាំមើល បើសិនជាកុមារឆ្លើយតបទៅសម្លេងនោះ ។

បើសិនជាកុមារឆ្លើយតបទៅសម្លេងកំរិតកណ្តាលនោះ ចូរគូសពីររង្វង់ ហើយឈប់ធ្វើតេស្តសម្លេងកំរិតកណ្តាលនៅត្រចៀកនោះទៀត ។ បើសិនជាកុមារមិនឆ្លើយតបទៅសម្លេងកំរិតកណ្តាល ចូរក្រឡុងកំប៉ុងឱ្យខ្លាំងប្រមាណបីបួនវិនាទី ដើម្បីបង្កើតសម្លេងកំរិតខ្លាំង ។ បើសិនជាកុមារឆ្លើយតបទៅសម្លេងកំរិតខ្លាំង ចូរគូសបីរង្វង់ក្នុងប្រអប់ដែលត្រឹមត្រូវលើតារាង ។ បើសិនជាកុមារមិនបានឮសម្លេង កុំគូសរង្វង់ក្នុងប្រអប់ ។ ចូរធ្វើឱ្យប្រាកដប្រជា ដើម្បីពិនិត្យត្រចៀកទាំងពីរជាមួយសម្លេងទាំងបីប្រភេទ :-

- សូរសម្លេង**កំរិតទាប** ស្ងាត់ ឬថ្នម (កំប៉ុងមានបំណែកឈើ)
- សូរសម្លេង**កំរិតកណ្តាល** (កំប៉ុងមានគ្រាប់សណ្តែក)
- សូរសម្លេង**កំរិតខ្ពស់** (កំប៉ុងមានគ្រាប់អង្ករ)

### នៅពេលអ្នកធ្វើតេស្តចប់ហើយ

ពិនិត្យមើលគំរូនៃការស្តាប់ឮ ។ វាអាចខុសៗគ្នាចំពោះកុមារម្នាក់ៗ ។




កុមារម្នាក់នេះ បានឮសូរសម្លេងកំរិតទាបល្អជាងសូរសម្លេងកំរិតខ្ពស់ ។

សូរសម្លេងកំរិតខ្ពស់ត្រូវតែធ្វើឱ្យខ្លាំងបន្តិច ដើម្បីឱ្យកុមារបានឮវា ។ កុមារក៏បានស្តាប់ឮនៅត្រចៀកខាងស្តាំល្អជាងត្រចៀកខាងឆ្វេងផងដែរ ។




កុមារម្នាក់នេះ ស្ទើរតែថ្លង់ទាំងស្រុងទៅហើយ ។

ត្រចៀកខាងឆ្វេងរបស់កុមារម្នាក់នេះ មិនអាចស្តាប់ឮសម្លេងសោះ ។ កុមារអាចស្តាប់ឮតិចតួចនៅត្រចៀកខាងស្តាំ ប៉ុន្តែបានឮសូរសម្លេងកំរិតទាបដែលខ្លាំងតែប៉ុណ្ណោះ ។

| | | | | | |
|---|---|---|---|---|---|
| ○ | សម្លេងថ្នម | ◎ | សម្លេងកណ្តាល | ◎ | សម្លេងខ្លាំង |

# ដើម្បីបានលទ្ធផលល្អបំផុត

**ឪពុកម្តាយ** គួរតែ :-

- ទប់ជំហារកុមារឱ្យនឹងនៅលើភ្លៅរបស់គាត់ តែអនុញ្ញាតឱ្យកុមារអាចបែរជុំវិញបានគ្រប់គ្រាន់ ។
- កុំឆ្លើយតបទៅសម្លេងទាំងឡាយ ដែលអ្នកធ្វើតេស្តបានធ្វើ ។



**អ្នកធ្វើតេស្ត** គួរតែ :-

- នៅពីក្រោយកុមារ ។
- ធ្វើសម្លេងស្មើនឹងកំពស់ត្រចៀកកុមារ ។
- ធ្វើសម្លេងនៅចម្ងាយមួយម៉ែត្រពីកុមារ ។
- កុំឱ្យកុមារ**ឃើញ**គាត់ ឬឃើញស្រមោលគាត់ ។ ឬអ្វីដែលអាចឆ្លុះឃើញគាត់ ។
- ធ្វើសម្លេងនៅត្រចៀកខាង**ឆ្វេង** និងត្រចៀកខាង**ស្តាំ**របស់កុមារ ។



**អ្នកជួយ** គួរតែ :-

- ធ្វើយ៉ាងណារក្សាការយកចិត្តទុកដាក់របស់កុមារជាមួយនឹងប្រដាប់លេង ។
- តាំងចិត្តឱ្យស្ងប់ និងនៅស្ងៀមស្ងាត់ ។
- កុំមើលទៅអ្នកធ្វើតេស្ត ។
- កុំឆ្លើយតបទៅសម្លេងទាំងឡាយ ដែលអ្នកធ្វើតេស្តបានធ្វើ ។



## 56 តើកូនអ្នកអាចស្ដាប់ឮអ្វីខ្លះ?

### តើកុមារអាចឮសម្លេង "និយាយ" ឬទេ?

សម្លេង "និយាយ" ក៏មានកំរិតសូរសម្លេងខុសប្លែកពីគ្នាផងដែរ។ ឧទាហរណ៍សម្លេងនិយាយ "ធ" "ដ" "ស" "ឈ" មានកំរិតសូរខ្ពស់ជាងសម្លេង "អ៊ូ" "អ៊ី" និង "ម"។ នេះមានន័យថា កូនអ្នកប្រហែលជាអាចស្ដាប់ឮសម្លេងនិយាយខ្លះៗ ប៉ុន្តែមិនឮអ្វីផ្សេងក្រៅពីនេះទេ។

វានឹងជួយអ្នកឱ្យបានដឹងបើសិនជាកូនអាចស្ដាប់ឮសម្លេងនិយាយកំរិតខ្ពស់ កណ្ដាល ឬទាប និងថាតើកំរិតសម្លេងទាំងនោះត្រូវឮខ្លាំងប៉ុណ្ណាដើម្បីឱ្យកុមារស្ដាប់ឮវា។ ព្យាយាមសំគាល់មើលសម្លេងដែលកុមារទំនងជាស្ដាប់ឮ ពេលសមាជិកគ្រួសារនិយាយគ្នា។

មើលទៅកុមារទំនងជាយល់ពាក្យ តែការពិតគឺស្ថានភាពសោះដែលធ្វើឱ្យន័យនោះច្បាស់លាស់។ បើមនុស្សម្នាក់និយាយថា "ទៅរើសបាល់" អំឡុងពេលគាត់ចង្អុល ឬមើលទៅបាល់ នោះកុមារអាចដឹងថាទៅរើសបាល់។ ក្មេងអាចមិនបានឮពាក្យនិយាយ តែគេបានឃើញមនុស្សចង្អុលទៅបាល់។ ប្រើវត្ថុបីបួនមុខដែលធ្លាប់ស្គាល់ដើម្បីលេងល្បែងមួយ ឬនាំកុមារលេងជារបៀបអនុវត្តសកម្មភាពប្រចាំថ្ងៃណាមួយដែលកុមារដឹងរួចហើយ។ ធ្វើបែបនេះពីរបីដងដើម្បីរកឱ្យឃើញថា ក្មេងអាចឮពាក្យនិយាយ ឬក៏មិនអាចឮ បើសិនជាកុមារបានស្ដាប់ឮឈ្មោះនៃវត្ថុទាំងនោះ។

**ដំបូង គ្រាន់តែនិយាយពាក្យ កុំធ្វើតម្រុយអ្វីឱ្យកុមារដឹង។**




**បើសិនជាកូនអ្នកមិនយល់ពាក្យនិយាយដែលមិនប្រើទឹកមុខ ឬសញ្ញារួមផ្សំ បន្ទាប់មកនិយាយពាក្យ និងមើលទៅវត្ថុនោះ។**




ជួនកាល មើលទៅកូនអ្នកទំនងជាឮសម្លេងខ្លះ តែមិនឮជានិច្ចនោះទេ។ កូនស្ដាប់មិនឮអ្នកនិយាយ មិនមានន័យថាកូនអ្នកក្បាលរឹងនោះទេ។ កូនពិតជាមិនឮអ្នកនិយាយមែន។ មានបញ្ហាច្រើនយ៉ាងដែលមានឥទ្ធិពលដល់ការឆ្លើយតបទៅសម្លេងរបស់ក្មេង ដូចជាពេលវេលា កុមារឃ្លាន អារម្មណ៍កុមារនៅថ្ងៃនោះ។ ជំងឺផ្ដាសាយ និងរលាកត្រចៀកក៏អាចប៉ះពាល់ដល់ការស្ដាប់របស់កុមារជាបណ្ដោះអាសន្នផងដែរ។

**បើសិនជាកូនអ្នកនៅតែមិនយល់ ចូរនិយាយពាក្យ បន្ទាប់មក មើល និងចង្អុលទៅវត្ថុនោះ។**



### ▶ ពិនិត្យសម្លេងនិយាយដែលទារក ឬកុមារអាចស្តាប់ឮ

ការធ្វើត្តេសសម្លេងនិយាយ អ្នកធ្វើតេស្តអនុវត្តដោយប្រើសម្លេងគាត់ផ្ទាល់ ជំនួសការក្រឡុកកំប៉ុងធ្វើសម្លេង។ នៅក្នុងការធ្វើតេស្តនេះ អ្នកប្រើសម្លេងនិយាយសាមញ្ញៗ :-

1. សម្លេង "ម" (ច្រៀងរហ៊ឹមតិចៗ) (សូរសម្លេងកំរិតទាប)។

2. សម្លេង "អ៊ូ" (អ៊ូ ដូចជាសម្លេងក្នុងពាក្យពូត) (សូរសម្លេងកំរិតកណ្តាល)។

3. សម្លេង "ស" (បន្លឺសម្លេងស៊ីៗៗៗដូចសត្វពស់) (សូរសម្លេងកំរិតខ្ពស់)។

សម្លេងថ្នមគួរតែធ្វើឱ្យបានស្ងាត់តាមដែលអាចធ្វើបាន។ ចូរស្នើឱ្យមនុស្សស្តាប់ឮធម្មតាជួយស្តាប់អ្នកធ្វើសម្លេង និងប្រាប់អ្នកវិញ បើសិនជាគាត់បានឮសម្លេងខ្សឹប (ថ្នម) ដែលអ្នកបាននិយាយ។




ការធ្វើតេស្ត គឺត្រូវអនុវត្តដូចគ្នាពេលធ្វើត្តេសសម្លេងខ្លាំង និងធ្វើតេស្តកំរិតសូរសម្លេង។ អ្នកចាប់ផ្តើមនឹងសូរសម្លេងកំរិតទាបបំផុត "ម" ធ្វើសម្លេងថ្នមនៅពីក្រោយត្រចៀកខាងឆ្វេងរបស់កុមារចំនួនបីបួនវិនាទី។ បន្តធ្វើវិធីដូចគ្នានេះ ពីសម្លេងថ្នមតិចៗទៅសម្លេងខ្លាំងឡើងៗនៅត្រចៀកខាងឆ្វេង បន្ទាប់មកត្រចៀកខាងស្តាំ និងពីសូរសម្លេងកំរិតទាប ទៅសូរសម្លេងកំរិតខ្ពស់។ ចូរប្រយ័ត្ន កុំបង្កើនកំរិតពេលអ្នកបង្កើនភាពខ្លាំងនៃសម្លេង។

## កុមារក៏អាចជួយបានដែរ

កុមារក៏អាចបំពេញនាទីសំខាន់ នៅក្នុងការជួយពិនិត្យការស្តាប់ឮរបស់បងប្អូនប្រុស ស្រី និងកុមារដទៃទៀត ក្នុងសហគមន៍ផងដែរ។

### ▶ របៀបពិនិត្យទារកអាយុបួនខែ និងអាយុច្រើនជាងនេះ



- ក្រឡុកចង្រ្កង់ធ្វើពីកំប៉ុង ឬផ្លែឃ្លោកទុំ ដោយដាក់គ្រាប់គ្រួសតូចៗនៅខាងក្នុង។ កុមារម្នាក់អាចលបៗយ៉ាងស្ងាត់ពីក្រោយទារក។ ដំបូងកុមារនោះ ត្រូវធ្វើយ៉ាងណាកុំឱ្យទារកឃើញ។ ដំបូង ក្រឡុកចង្រ្កង់នៅខាងក្រោយក្បាលទារក នៅចំហៀងខ្លួនម្ខាង និងបន្ទាប់មកនៅចំហៀងម្ខាងទៀតនៃទារក។ សំគាល់មើល បើសិនជាទារកភ្ញាក់ផ្អើល។
- ហៅឈ្មោះទារកនៅកន្លែងខុសៗគ្នាក្នុងបន្ទប់។ សំគាល់មើល បើសិនជាទារកឆ្លើយតបក្នុងវិធីណាខ្លះ។



## ▶ វិធីពិនិត្យការស្ដាប់របស់កុមារតូចៗ

### លេងល្បែង: នោះជាសត្វអ្វី?

តែងតាំងកុមារម្នាក់ជាអ្នកនិយាយ និងឱ្យកុមារនោះឈរចម្ងាយប្រមាណបួនម៉ែត្រពីកុមារតូចៗមួយជួរ។ នៅពីក្រោយកុមារតូចម្នាក់ៗ មានកុមារធំឈរពីក្រោយ ដោយមានកាន់ខ្មៅដៃ និងក្រដាស់។




ដំបូងអ្នកនិយាយប្រើសម្លេងនិយាយឱ្យឮខ្លាំងៗ ដើម្បីនិយាយឈ្មោះសត្វសាមញ្ញមួយ។ កុមារតូចៗនិយាយខ្សិបៗនូវឈ្មោះសត្វដែលខ្លួនបានស្ដាប់ឮប្រាប់ទៅក្មេងធំៗជាដៃគូឈរពីក្រោយ។ កុមារធំៗសរសេរលើក្រដាសនូវអ្វីដែលខ្លួនបានស្ដាប់ឮពីកុមារតូចៗ។

បន្ទាប់មកអ្នកនិយាយ ត្រូវហៅឈ្មោះសត្វដទៃទៀតម្ដងមួយៗ ដោយបន្ថយសម្លេងឱ្យស្ងាត់បន្តិចម្ដងៗទាល់តែទៅជាសម្លេងខ្សិបៗ។ កុមារធំៗសរសេរគ្រប់ឈ្មោះសត្វទាំងអស់ ដែលកុមារតូចៗបានប្រាប់ពួកគេ។

ក្រោយពេលដែលអ្នកនិយាយ ហៅឈ្មោះបានប្រហែល 10សត្វ ហើយពាក្យទាំងអស់របស់កុមារតូចៗបានកត់ត្រារួចហើយ ចូរប្រៀបធៀបកំណត់ហេតុទាំងនោះ។ កុមារណាម្នាក់ដែលមិនឮពាក្យបានច្រើនដូចកុមារផ្សេងៗទៀត ឬស្ដាប់ឮពាក្យមិនត្រឹមត្រូវ កុមារនោះអាចមានបញ្ហាស្ដាប់។

## តេស្តដែលអាចធ្វើបាននៅមជ្ឈមណ្ឌលសុខភាព



គ្លីនិក ឬមណ្ឌលសុខភាពក៏អាចជួយធ្វើតេស្តឱ្យកូនអ្នកបានដែរ។ ការធ្វើតេស្តបៀបនេះអាចមានប្រយោជន៍ បើសិនជាអ្នកគិតថា កូនមានការលំបាកក្នុងការស្ដាប់តែអ្នកមិនអាចរៀបរាប់កើតថា តើសម្លេងប្រភេទណាមួយដែលកូនអាចស្ដាប់ឮ បើសិនជាមាន ។

គួរឱ្យស្ដាយ គ្លីនិកដែលអាចធ្វើតេស្តការស្ដាប់នៅសែនឆ្ងាយ ឬក៏ថ្លៃពេក។ ប៉ុន្តែអ្នកឯកទេសពិតជាត្រូវការចាំបាច់ បើសិនជាកូនអ្នកត្រូវប្រើឧបករណ៍ជំនួយការស្ដាប់ ។

បើសិនជាអ្នកបានធ្វើតេស្តការស្ដាប់របស់កូនដោយខ្លួនឯងរួចហើយនៅកន្លែងធ្លាប់ស្គាល់ កូនអាចមិនសូវខ្លាចពេលកូនត្រូវបានធ្វើតេស្តដោយមនុស្សចម្លែក និងនៅកន្លែងមិនដែលស្គាល់។ កូនអាចសហការបានជិតស្និត ហើយអាចយល់បានច្រើនពីអ្វីដែលខ្លួនត្រូវធ្វើ។ ព័ត៌មានអំពីធ្វើតេស្តការស្ដាប់ គឺយកទៅប្រើដើម្បីផលិតឧបករណ៍ជំនួយការស្ដាប់តម្រូវតាមការស្ដាប់ឮរបស់កុមារ។ ព័ត៌មានបន្ថែមអំពីឧបករណ៍ជំនួយការស្ដាប់ សូមអានទំព័រ217 ដល់ទំព័រ224។

## ត្រូវធ្វើអ្វីជាមួយព័ត៌មាននេះ

បើសិនជាកូនអាចនៅស្ដាប់ឮសម្លេងខ្លះៗ អ្នកអាចជួយកូនឱ្យចេះប្រើការស្ដាប់បានល្អប្រសើរ។ សូមអានជំពូកបន្ទាប់ទៀតស្ដីពីការអភិវឌ្ឍបំណិនការស្ដាប់។ បើសិនជាអ្នកនៅតែទទួលលទ្ធផលដដែល ក្រោយពីអនុវត្តបំណិនការស្ដាប់របស់កូនបានចំនួន 6ខែ ចូរពិនិត្យការស្ដាប់របស់កូនម្ដងទៀត ដើម្បីឱ្យឃើញលទ្ធផលដូចលើកដំបូង ឬយ៉ាងណា ។